# ការកែសម្រួលឡើងវិញអំពីគោលការណ៍ណែនាំសម្រាប់ក្រុមគ្រួសារនៅពេលបើកសាលារៀន
# 2021-22



## សាលារៀនចាប់ផ្តើមបើកនៅថ្ងៃទី៣ ខែសីហា

ទាក់ទងសាលារៀននៃសិស្សរបស់លោកអ្នក ដើម្បីទទួលចម្លើយជាបន្ថែម

# ឆ្នាំសិក្សាដ៏រំភើបរង់ចាំទទួល

ជម្រាបជូនក្រុមគ្រួសារនៃក្រសួងអប់រំ ឱស្ទ្រីត ឡុងប៊ីច,



យើងមានសេចក្តីរីករាយអំពីការផ្តល់ជូនកម្មវិធីរៀនពេញថ្ងៃ តាមរយៈការបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់សម្រាប់ឆមាសក្នុងរដូវស្លឹកឈើជ្រុះ ។ យើងដឹងថា ចំពោះសិស្សភាគច្រើន ការបង្ហាត់មេរៀននៅក្នុងថ្នាក់ផ្ទាល់ គឺជាមធ្យោបាយពិសេសជាងគេសម្រាប់ការរៀន ។ គ្រូបង្រៀន និង បុគ្គលិកទូទៅរបស់យើងមានការប្តេជ្ញាចិត្តបើកសាលារៀនឡើងវិញ ស្របដោយសុវត្ថិភាពជាច្រើនបំផុត ។ នៅក្នុងរដូវក្តៅកន្លងមក យើងបានបើកកម្មវិធីបង្ហាត់យ៉ាងជោគជ័យទៅកាន់សិស្សជាង 14,000 នាក់នៅតាមសាលារៀនរបស់យើង ហើយយើងនៅតែបន្តធ្វើតាមទម្រង់ការផ្នែកសុខភាព និង សុវត្ថិភាពដោយប្រយ័ត្នប្រយែង ដើម្បីជួយបន្ថយការរាលដាលនៃជម្ងឺ កូវីដ ។

គោលការណ៍ណែនាំខ្លីៗនេះធ្វើការសង្ខេបអំពីចំណុចសំខាន់ៗទាក់ទងផ្នែកសុវត្ថិភាព និង ផ្តល់ជាមធ្យោបាយចំណាំទុក នៅពេលយើងរង់ចាំដល់ថ្ងៃចូលរៀនលើកដំបូងក្នុងឆ្នាំសិក្សាថ្មី ។ មកទល់ពេលឥឡូវ យោងទៅតាមក្បួនណែនាំពីក្រសួងសុខាភិបាលនៃក្រុង ឡុងប៊ីច គឺសិស្ស និង បុគ្គលិកត្រូវពាក់គម្របមុខនៅពេលចូលទៅក្នុងអាគារនៅតាមសាលារៀន ។ ម្នាក់ៗនឹងទទួលការស្នើសុំឱ្យឆ្លើយប្រាប់អំពីរោគសញ្ញា កូវីដ មុននឹងទៅដល់សាលារៀន ។ បុគ្គលិកនឹងទទួលការស្នើសុំឱ្យបង្ហាញជាក្រដាសចាក់ថ្នាំ កូវីដ ឬ បង្ហាញលទ្ធផលអំពីការធ្វើ តេស្ត កូវីដ ប្រចាំសប្តាហ៍ ។ យើងក៏នឹងធ្វើ តេស្ត កូវីដ ផងដែរទៅកាន់សិស្សទាំងអស់ ដែលមិនបានចាក់ថ្នាំ ដើម្បីការពារជម្ងឺ កូវីដ ។ មកទល់ពេលឥឡូវនេះ គឺគ្មានការតម្រូវអ្វីទេសម្រាប់ឱ្យនៅដាច់ៗពីគ្នា ប៉ុន្តែ យើងនឹងជម្រុញឱ្យសិស្សធ្វើស្របទៅតាមទីកន្លែង ។

យើងទទួលស្គាល់ថា ក្រុមគ្រួសារបានឆ្លងកាត់បទពិសោធន៍លំបាកជាច្រើននៅពេលមួយឆ្នាំកន្លងមក ។ ដើម្បីដោះស្រាយបញ្ហាផ្នែកអារម្មណ៍ និង ផ្លូវចិត្ត និង ដើម្បីលៃលកជួយសិស្សឱ្យមានជាជំនួយផ្នែកសិក្សាសម្រាប់នាំមកជាលទ្ធផល គឺយើងបានរៀបចំ គម្រោងបង្កើនល្បឿនសិក្សា និង ផ្តល់ជំនួយទូទៅ ដែលអាចបើកមើលបាននៅតាម lbschools.net ។ គម្រោងយល់ដឹងនេះ ដែលធ្វើការសង្កត់មកលើផ្នែកឧត្តមភាព និង សមធម៌ ត្រូវបានបង្កើតឡើងតាមរយៈទទួលយោបល់មកវិញពីសហគមន៍ ដែលរាប់បញ្ចូលផងទាំងក្រុមប្រឹក្សា និង ដៃគូជាច្រើននៅតាមតំបន់ និង កម្រិតជាតិ ។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រៅជ្រះចំពោះជំនួយទ្រទ្រង់ពីលោកអ្នក នៅពេលយើងសម្លឹងទៅមុខ ភ្ជាប់ដោយទឹកចិត្តដ៏រំភើបទៅកាន់ឆ្នាំសិក្សា និង ពេលវេលាថ្មីសម្រាប់លទ្ធផលលូតលាស់ដល់សិស្សរបស់យើង ។

ដោយភាពកក់ក្តៅ,



Jill A. Baker, Ed. D.
អគ្គនាយកសាលារៀន

ត្រូវបានកែសម្រួលឡើងវិញនៅខែសីហា 2021

# ការប្តេជ្ញាចិត្តរបស់យើងទៅកាន់សុវត្ថិភាព

## ក្បួនណែនាំពីក្រសួងសុខាភិបាល

ក្រសួងអប់រំ ឪស្រ្ទីត ឡុងប៊ីច នឹងបន្តការធ្វើតាមក្បួនណែនាំថ្មីៗ ដែលទើបបានបញ្ចេញមកពីក្រសួងសុខាភិបាលប្រចាំរដ្ឋ កាលីហ្វ័រញ៉ា និង ក្រសួងសុខាភិបាលប្រចាំក្រុង ឡុងប៊ីច ។

## មធ្យោបាយការពារជម្ងឺ កូវីដ-១៩ (COVID-19)

- គម្របមុខ: ទាំងបុគ្គលិក ទាំងសិស្សនឹងទទួលការតម្រូវពាក់គម្របមុខនៅក្នុងអាគារ
- ការនៅដាច់ៗពីគ្នា គឺធ្វើស្របតាមទំហំក្នុងបន្ទប់និមួយៗ
- ការប្រើឧបករណ៍ទំនើបសម្រាប់បញ្ចេញខ្យល់ចេញចូល
- បុគ្គលិក និង សិស្សនឹងសម្រាកនៅផ្ទះ ពេលណាមានជម្ងឺ ដែលបង្ហាញជាសញ្ញាស្រដៀង កូវីដ
- ការជូតសំអាត និង លាងដៃ
- ការបង្ហាញក្រដាសចាក់ថ្នាំ និង/ឬ ការធ្វើ តែស្ត កូវីដ
- ការរាយប្រាប់ ការតាមដាន និង ការឃាត់ទុកនៅផ្ទះសម្រាប់បុគ្គលិក ឬ សិស្ស

## ព័ត៌មានអំពីកាតចាក់ថ្នាំ

មានបុគ្គលិក LBUSD រាប់ពាន់នាក់បានទទួលការចាក់ថ្នាំពេញកម្រិតរួចហើយកាលពីរដូវផ្ការីក 2021 ដើម្បីទប់ទល់ជម្ងឺ កូវីដ ។ ឥឡូវនេះ ក្រសួងអប់រំ ឪស្រ្ទីត កំពុងធ្វើការតម្រូវសុំឱ្យបុគ្គលិកបង្ហាញជាក្រដាសចាក់ថ្នាំ កូវីដ ឬ ទទួលធ្វើ តែស្ត កូវីដ ប្រចាំសប្តាហ៍ ។ សិស្សអាយុពី 12 ឆ្នាំ ឡើងទៅ និង ក្រុមគ្រួសាររបស់ពួកគេអាចទៅទទួលការចាក់ថ្នាំបាននៅតាមមន្ទីរ គ្លិននិក ជាច្រើនកន្លែងក្នុងសហគមន៍ ។ នៅពេលឆ្នាំសិក្សាផ្តើមឡើង គឺក្រសួងអប់រំ LBUSD នឹងធ្វើ តែស្ត កូវីដ ទៅកាន់សិស្សទាំងឡាយណា ដែលមិនបានទទួលការចាក់ថ្នាំ ។ ការធ្វើ តែស្ត គឺត្បារនៅពីមុខច្រមុះ ដែលក្រសួងអប់រំ LBUSD ធ្លាប់បានធ្វើជាមួយសិស្សរួចមកហើយកាលពីរដូវផ្ការីក 2021 កន្លងមកនៅពេលសាលារៀនបានផ្តើមបើកទ្វារឡើងវិញ ។ ក្រសួងអប់រំ LBUSD នឹងបន្តសហការណ៍ជាមួយក្រសួងសុខាភិបាល ឡុងប៊ីច ដើម្បីផ្តល់ការចាក់ថ្នាំនៅតាមសាលារៀន ។ បណ្ណិ អនឡាញ ដែលមានព័ត៌មានអំពីកន្លែងចាក់ថ្នាំ គឺបានផ្ញើទៅកាន់ក្រុមគ្រួសារតាមរយៈ អ៊ីមែល ។ បណ្ណិក៏មានតាំងបង្ហាញផងដែរនៅតាម គេហទំព័រ ក្នុងសាលារៀននិមួយៗ ។ (ជ្រើសរើសយក peachjar ដើម្បីសំគាល់មើលអំពីបណ្ណិរាយបង្ហាញ អនឡាញ) ។



## ឧបករណ៍ប្រើការពារខ្លួន

តទៅនេះ គឺជាឧបករណ៍មាននៅតាមសាលារៀនសម្រាប់ប្រើ ស្របតាមសេចក្តីត្រូវការនៃបុគ្គលិក និង សិស្ស:

- គម្របមុខជាជាតិក្រណាត់ ឬ ភ្លីផ្លា
- គម្របមុខពាក់ហើយចោល
- គម្របមុខ N95/KN95 សម្រាប់បុគ្គលិកមួយចំនួន
- របាំងមុខសម្រាប់បុគ្គលិក និង សិស្សមួយចំនួន
- អាល់កុលជូតសំអាតដៃ
- សំលៀកបំពាក់/ស្រោមដៃពាក់ហើយចោលសម្រាប់បុគ្គលិកមួយចំនួន
- ក្រដាសជូត និង លាងសំអាត

## ការពិនិត្យសុខភាពខ្លួនឯងនៅតាមផ្ទះ



មាតាបិតានឹងទទួលការរំលឹកឱ្យជួយឃ្លាំមើលរាល់ថ្ងៃអំពីរោគសញ្ញា មុននឹងបញ្ជូនសិស្សទៅសាលារៀនៈ

- គ្រុនក្តៅ ដែលមានកម្តៅ 100.4° F ឬ លើស
- ក្អក ឈឺ ក តឹងច្រមុះ ឬ ហៀរសំបោរ
- ស្ទើរដង្ហើម ឬ ពិបាកដកដង្ហើម
- បាត់បង់រសជាតិ ឬ ជាតិក្លិន
- រងា ឬ ឈឺខ្លួន
- ដំណើរចង់ក្អួត ក្អួត ឬ ចុករាគ

សម្រាកនៅផ្ទះ បើមានជម្ងឺ ។

## ចម្លើយប្រាប់ និង ការរាយបង្ហាញជម្ងឺ កូវីដ



ចំពោះសិស្ស ដែលត្រូវបានរកឃើញថា មានរោគសញ្ញា កូវីដ នៅពេលទៅដល់សាលារៀន ឬ នៅក្នុងពេលកំពុងតែរៀន គឺនឹងទទួលការបញ្ជូនទៅកាន់បន្ទប់ CARE Room ។ បុគ្គលិកនឹងទាក់ទងមាតាបិតា ឬ អ្នកគ្រប់គ្រងនៃសិស្សឱ្យទៅទទួលដកសិស្សចេញពីសាលារៀនភ្លាម ។ សាលារៀននិមួយៗនឹងមានបន្ទប់ CARE Room ដែលមានបុគ្គលិកយល់ដឹងច្បាស់លាស់នៅមើលខុសត្រូវ ។

ក្រសួងអប់រំ LBUSD បានតែងតាំងបុគ្គលិកសម្រាប់ផ្តល់ជំនួយសម្រាប់ដោះស្រាយ និង គ្រប់គ្រងផ្នែក កូវីដ រួមទាំងផ្តល់ជាលេខទាក់ទងទៅកាន់ផង ដែលមានជា (562) 204-6075 បើសិនមានបញ្ហាផ្សេងៗនឹកចង់សួរ ។

នៅតាម Dashboard នៃក្រសួងអប់រំ ឪស្រ្ទីត ដែលអាចបើកមើលបាននៅតាម lbschools.net គឺមានការតាំងបង្ហាញចំនួនឆ្លងជម្ងឺជាលទ្ធផល positive នៅតាមសាលារៀននិមួយៗ ។ នៅពេលដឹងអំពីលទ្ធផល positive មួយហើយ គឺនឹងមានការផ្តល់ដំណឹងអំពីសាលារៀននោះ ដែលមានទាំងការផ្ញើសំបុត្រជូនមាតាបិតាផង បើសិនចាំបាច់ ។

ទម្រង់ការប្រើតាមសម្រាប់ធ្វើការតាមដានអំពីជម្ងឺ កូវីដ គឺរាប់បញ្ចូលទាំងការចង់ដឹងអំពីមនុស្សម្នាទាំងអស់ ដែលបានស្ថិតនៅក្បែរ ដែលក្រសួងសុខាភិបាលប្រចាំរដ្ឋ កាលីហ្វ័រញ៉ា ចាត់ទុកថា បាននៅក្បែរគ្នាជិតជាង ប្រាំមួយ ហ្វ៊ីត លើសជាងចំនួន ដប់ប្រាំ នាទី ក្នុងរយៈពេល ម្ភៃបួន ម៉ោង ។ អ្វីបានចំណាយនៅក្បែរគ្នា ដែលអាចបង្កការឆ្លងជម្ងឺបាន គឺគួររាយបង្ហាញប្រាប់ក្នុងចំនួនពេល ម្ភៃបួន ម៉ោង ។

## ការឃាត់ទុកនៅក្នុងផ្ទះ



អនុសាសន៍ពីច្បាប់ក្នុងពេលឥឡូវសម្រាប់ប្រើឃាត់ទុកនៅផ្ទះ គឺសំដៅទៅលើពេល ដែលបានចំណាយនៅក្បែរមនុស្សមិនទាន់ចាក់ថ្នាំ ឬសិស្សមិនទាន់ចាក់ថ្នាំ ដែលប្រហែលជាមិនបង្ហាញរោគសញ្ញា ។

ការឃាត់ទុកនៅផ្ទះ គឺអាចបញ្ចប់បាន បន្ទាប់ពីរយៈពេល ដប់ ថ្ងៃផុតទៅ ចាប់តាំងពីបានទទួលការឆ្លងក្នុងពេលចុងក្រោយមក ដោយមិនបានធ្វើ តែស្ត ឬ បន្ទាប់ពី ប្រាំពីរ ថ្ងៃផុតទៅ បើសិនបានធ្វើ តែស្ត បន្ទាប់ពីរយៈពេល ប្រាំ ថ្ងៃ ចាប់តាំងពីថ្ងៃចុងក្រោយ ដែលបានទទួលការឆ្លង ហើយលទ្ធផលធ្វើ តែស្ត បានបង្ហាញជា negative ។

## គុណភាពនៃខ្យល់នៅផ្នែកខាងក្នុង



ក្រសួងសុខាភិបាលជាតិផ្តល់អនុសាសន៍មកលើការបង្កើនប្រើគុណភាពខ្ពស់នៃតម្រង (គោលដៅគឺ MERV13) ដើម្បីការពារបញ្ហារាំងស្ទះដល់ខ្យល់ហើរចេញចូល និង រៀបជាគម្រោងបន្ថែមសម្រាប់ដោះស្រាយគុណភាពខ្យល់នៅក្នុងអាគារ ។ MERV ជាអក្សរកាត់ស្រមាប់ Minimum Efficiency Reporting Values ។

មានម៉ាស៊ីនត្រជាក់/កម្តៅពិសេសត្រូវបានចែកទៅកាន់សាលារៀនទាំងឡាយណា ដែលមានម៉ាស៊ីនមិនអាចប្រើតម្រង MERV13 បាន ។

ម៉ាស៊ីនត្រជាក់/កម្តៅទាំងអស់ត្រូវបានរៀបចំតម្លើង ដែលអាចប្រើតម្រងម៉ាក MERV-16 បាន ។ នេះជាតម្រងមានគុណភាពខ្ពស់ជាងគេ ដែលពេញនិយមប្រើនៅតាមក្រសួងធំៗ ។

## ការចំណាំទុកអំពីពេលត្រឡប់ចូលរៀនវិញ

- **បើកមើលនៅតាម lbschools.net/coronavirus** ដើម្បីចំណាំទុកព័ត៌មានថ្មីៗទាក់ទងជម្ងឺ COVID និង ពេលបើកសាលារៀនឡើងវិញ ដែលមានទាំងសារនៅក្នុង វិដេអូ ពីអគ្គនាយកសាលារៀន រួមទាំងជំនួយផ្សេងៗទៀតផងអាចស្វែងរកបាន ។

- **លែលកជួយសិស្សរបស់លោកអ្នកឱ្យមានជាគម្របមុខស្អាត**សម្រាប់ពាក់ក្នុងសាលារៀន ។ គម្របមុខ គឺត្រូវពាក់ក្នុងសាលារៀន ស្របតាមក្បួនណែនាំ លើកលែងពេលទទួលអាហារ ។

- **នាំសមាជិកក្នុងក្រុមគ្រួសារទៅទទួលការចាក់ថ្នាំ**
ក្រសួងសុខាភិបាលចាត់ទុកថា ការចាក់ថ្នាំសម្រាប់មនុស្សអាយុ 12 ឆ្នាំឡើងទៅ គឺគ្មានបង្ករបញ្ហា និង មានភាពស័ក្តសិទ្ធ ។ ការចាក់ថ្នាំមានសារសំខាន់ក្នុងការជួយការពារលោកអ្នក និងមនុស្សដ៏ទៃ ។ សូម្បីតែក្នុងពេលឥឡូវនេះ ដែលគ្មានការតម្រូវឱ្យចាក់ថ្នាំពិតមែនសម្រាប់បុគ្គលិក ឬ សិស្ស ក៏យើងនៅតែសុំជម្រុញដល់សមាជិកក្នុងសហគមន៍ភាគច្រើនឱ្យទៅទទួលការចាក់ថ្នាំ COVID-19 ។

- **ចុះឈ្មោះប្រើ និង ធ្វើការកែតម្រូវព័ត៌មានផ្សេងៗរបស់លោកអ្នកនៅក្នុង ParentVUE ។**
នេះជាការងាយសម្រាប់មាតាបិតាបើកមើលព័ត៌មានអំពីសិស្សរបស់ពួកគាត់នៅពេលសព្វថ្ងៃ និង ពីពេលកន្លងមក ដូចជាៈ លេខពិន្ទុ និង ចំនួនថ្ងៃចូលរៀន /ល/ ។ សូមទាក់ទងសាលារៀននៃសិស្សរបស់លោកអ្នក បើសិនជាត្រូវការជំនួយបង្ហាញរបៀបត្រូវធ្វើ ។

- **ហាត់ធ្វើតាមទម្លាប់ថ្មី** ។ ទម្លាប់ប្រចាំថ្ងៃ ដូចជាៈ ការក្រោកនៅពេលព្រឹក និង ស្លៀកពាក់ទាន់ពេល ការពាក់គម្របមុខ ការទទួលអាហារស្របពេល រួមទាំងការរៀនសុំាជាមួយមនុស្សធំ និង ក្មេងដ៏ទៃ គឺមានសារសំខាន់ណាស់សម្រាប់កិច្ចការទាំងអស់នៅពេលត្រឡប់ចូលសាលារៀនវិញ ។





